ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ...១២១៥.សជណ

ថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំ
# របស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា
# ថ្ងៃពុធ ១០រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣

កាលពីថ្ងៃពុធ ១០រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ វេលាម៉ោង ៨និង៣០នាទី នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី មានរៀបចំកិច្ចប្រជុំគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ជ.វ.**) របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

រាជរដ្ឋាភិបាលបានសម្រេច៖

១- បន្តអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈដែលបានអនុវត្តកន្លងមក ដែលមានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ដើម្បីសម្រេចឱ្យបានជាលទ្ធផលជាក់ស្តែងក្នុងផ្នែកគន្លឹះនៃរដ្ឋបាលសាធារណៈ ដោយផ្តោតលើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន តាមរយៈវិធានការជាក់ស្តែង រួមមាន៖

១.១- ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព។

១.២- ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

១.៣- ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

២- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ប្រកាន់យករបៀបនៃការគិតគូរថ្មីប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ក្នុងការពិចារណាដោះស្រាយស្ថានភាពចំពោះមុខពាក់ព័ន្ធនឹងការគ្រប់គ្រងនិងប្រើប្រាស់ធនធានមនុស្ស ដោយត្រូវអនុវត្តការត្រួតពិនិត្យឡើងវិញ ការវិភាគមុខងារស្ថាប័ន និងការកំណត់តម្រូវការធនធានមនុស្សឱ្យបានច្បាស់លាស់។

៣- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ធ្វើការពិនិត្យ កែសម្រួល និងតម្រង់ទិសថវិកាឱ្យចំគោលដៅ ដោយត្រូវពិនិត្យមើលប្រភពថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រប្រសិទ្ធភាពការងារ សមិទ្ធកម្ម និងការលើកទឹកចិត្តផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពខ្ពស់។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ធ្វើការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំក្នុងន័យកំណត់ឱ្យបានច្បាស់លាស់នូវបញ្ហាប្រឈម ដើម្បីងាយស្រួលក្នុងការសម្របសម្រួល និងការគាំទ្រដល់ក្រសួង ស្ថាប័ន ផ្អែកលើគោលការណ៍រដ្ឋាភិបាលឯកភាព រដ្ឋបាលឯកភាព និងសំឡេងឯកភាពតែ១ក្នុងការបំពេញការងារ។

៥- ប្រគល់ភារកិច្ចជូនក្រសួងមុខងារសាធារណៈក្នុងនាមជាលេខាធិការដ្ឋាន នៃ គ.វ.រ. ត្រូវជំរុញការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈដោយត្រូវបន្សី និងប្រទាក់ក្រឡាគ្នានូវសកម្មភាពនៃការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ព្រមទាំងការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ឱ្យបានរួចរាល់ត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ ដោយក្នុងនោះ៖

៥.១- ត្រូវរៀបចំការប្រឡងជ្រើសរើសមន្ត្រីរាជការដាច់ដោយឡែកពីគ្នា ផ្តល់ជម្រើសច្រើនដល់បេក្ខជន ព្រមទាំងត្រូវអនុវត្តស្របតាមគោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាលក្នុងក្របខណ្ឌនៃការកែទម្រង់រដ្ឋបាលសាធារណៈ។

៥.២- ត្រូវអនុវត្តឱ្យបានចប់សព្វគ្រប់នូវការពិនិត្យឡើងវិញរចនាសម្ព័ន្ធ និងការវិភាគមុខងាររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រឹមត្រីមាសទី៣ ឆ្នាំ២០២៤។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសមន្ត្រីរាជការឡើយ ក្នុងករណីមិនបានអនុវត្តការពិនិត្យឡើងវិញរចនាសម្ព័ន្ធនិងការវិភាគមុខងារ។

៥.៣- ត្រូវរៀបចំប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មក្នុងកម្រិតម៉ាក្រូ ដែលផ្តល់ការគាំទ្រពីរាជរដ្ឋាភិបាល ឱ្យបានរួចរាល់ត្រឹមត្រីមាសទី៣ ឆ្នាំ២០២៤។ ទន្ទឹមនេះ យន្តការលើកទឹកចិត្តផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្រាប់ត្រូវរក្សាទុក និងអនុវត្តដដែល។

៦- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ បង្កើតឱ្យមានក្រុមការងារទទួលបន្ទុកអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ឱ្យមានប្រសិទ្ធភាព ប្រកបដោយបរិយាប័ន្ន សង្គតិភាព និងយុត្តិធម៌។

៧- ប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ជំរុញការផ្លាស់ប្តូរផ្នត់គំនិត និងរបៀបបំពេញការងារតាមទម្លាប់ ដោយត្រូវរៀបចំ និងអនុវត្តតាមគោលការណ៍ណែនាំច្បាស់លាស់ ផ្អែកលើការពិគ្រោះយោបល់ទូលំទូលាយ និងឈរលើគោលការណ៍រួមចិត្ត រួមគំនិត និងរួមសកម្មភាព ដែលក្នុងនោះ៖

៧.១- ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤ ជាដំណាក់កាលពិនិត្យឡើងវិញ និងរៀបចំកិច្ចការឱ្យរៀបរយ។

៧.២- ពីឆ្នាំ២០២៥ ដល់ ឆ្នាំ២០២៦ ជាដំណាក់កាលអនុវត្តឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរ។

៧.៣- ពីឆ្នាំ២០២៧ ដល់ឆ្នាំ២០២៨ ជាដំណាក់កាលពិនិត្យ និងវាយតម្លៃដើម្បីពង្រឹងនិងពង្រីកការកែទម្រង់។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួងស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ពាក់ព័ន្ធត្រូវយកចិត្តទុកដាក់អនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**ចម្លងជូន ៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ